# តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញត្រូវបានប្រារព្ធពិធីបើកសម្ពោធជាផ្លូវការ



*ខ្លោងទ្វារដ៏ធំស្កឹមស្កៃនៃតំបន់សេដ្ឋកិច្ចពិសេស និងលោកជំទាវឧកញ៉ាលឹម ឈីវហួរ អគ្គនាយិកាក្រុមហ៊ុន (រូបថត អ៊ុយសុង)*

**រាជធានីភ្នំពេញ** ៖ កាលពីថ្ងៃទី១ កញ្ញា គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា បានសហការជាមួយក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រៀបចំពិធីបើកសម្ពោធជាផ្លូវការរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ក្រោមអធិបតីភាពលោកជា វុទ្ធី អគ្គលេខាធិការរងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងជាប្រធានរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ។

លោកជំទាវឧកញ៉ាលឹម ឈីវហួរ អគ្គនាយិកាក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញដែលហៅកាត់ថា PPSEZ បានថ្លែងថា តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ត្រូវបានសំរេចឱ្យបង្កើតដោយអនុក្រឹត្យលេខ៣៣ អនក្រ បក ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ដែលមានផ្ទៃដីទំហំ៣៥០ហិកតានិង១០ម៉ែត្រក្រឡា ហើយចែកជា៣ ដំណាក់កាលសំរាប់ការអភិវឌ្ឍន៍ ។ បច្ចុប្បន្ន PPSEZ បានសំរេចបញ្ចប់ការស្ថាបនាជាស្ថាពរនូវហេដ្ឋារចនាសម្ព័ន្ធក្នុងដំណាក់កាលទី១ តាមគំរោងអភិវឌ្ឍន៍ ។

PPSEZ គឺជាតំបន់ពិសេស ដែលជាទីចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេស ដោយទីតាំងរបស់ PPSEZ ស្ថិតនៅមិនឆ្ងាយពីទីប្រជុំជន មានលក្ខណៈងាយស្រួលក្នុងការស្រូបទាញយកកម្លាំងពលកម្មសំរាប់បំរើការងារក្នុងសហគ្រាស និងមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ដែលបង្កលក្ខណៈងាយស្រួលសំរាប់ការដឹកជញ្ជូន ទំនិញគ្រប់ប្រភេទពី PPSEZ ទៅផែអន្តរជាតិក្រុងព្រះសីហនុ ។

នាពេលបច្ចុប្បន្ននេះ មានក្រុមហ៊ុនវិនិយោគទាំងក្នុងនិងក្រៅប្រទេសចំនួន២០ បានចូលមកបណ្តាក់ទុនវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលក្នុងនោះមានក្រុមហ៊ុនចំនួន៩ បានបំពេញបែបបទស្នើសុំការអនុញ្ញាតលើគំរោងវិនិយោគរបស់ខ្លួន ហើយក្នុងនោះដែរ ក្រុមហ៊ុនចំនួន៧ បានទទួលការអនុញ្ញាតជាគោលការណ៍ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីអាចរៀបចំប្រតិបត្តិការនូវគំរោងវិនិយោគរបស់ខ្លួន ៕

**អ៊ុយសុខ**